កាលបរិច្ឆេទ: ថ្ងៃទី ០១ ខែឧសភា ឆ្នាំ២០១៨

# មេរៀនដាំដំណាំសណ្តែកក្តួរ (សណ្តែកទ្រើង)

សណ្តែកទ្រើងគឺជាដំណាំឬជាបន្លែដែលកសិករនិយមដាំ និង និយមបរិភោគពីព្រោះវាមានរសជាតិឆ្ងាញ់និងសម្បូរជីវជាតិសម្រាប់ទ្រទ្រង់សរីរាង្គកាយ មានដូចជា ជាតិទឹក ប្រូតេអ៊ីន ខ្លាញ់កាបូនអ៊ីត្រាតនិង កាលស្យូម។

## ១.ការជ្រើសរើសពូជ

ការជ្រើសរើសពូជជាកត្តាសំខាន់ដំបូងសំរាប់ការដាំដុះកំណត់ទិន្នផល និងតម្រូវការទីផ្សារ។

*កត្តាសំខាន់ៗដែលត្រូវកំណត់ជ្រើសរើសមានដូចជា៖*

- ពូជមានប្រភពច្បាស់លាស់ (ពូជក្នុងស្រុកឬពូជបង្កាត់)
- ពូជមានអាយុកាលត្រឹមត្រូវ
- ពូជដុះល្អពី៨៥-៩០%
- ពូជសុទ្ធល្អ
- ពូជធន់នឹងអាកាសធាតុ ធន់នឹងសត្វល្អិត និងធន់នឹងជម្ងឺ។

ចំពោះពូជបង្កាត់មិនអាចទុកពូជសម្រាប់ដាំបន្តបានទេ។

រៀបចំដោយលោក យុគ សឿង នាយករងរបស់អង្គការស៊ីអាវ៍ឌីណាស់ (CRDNASE)
កែសម្រួលអត្ថបទដោយ ស៊ុន សុគន្ធី មន្ត្រីគម្រោងរបស់អង្គការស៊ីអាវ៍ឌីណាស់ (CRDNASE)

# ២.បច្ចេកទេសដាំដុះ

## ២.១ ការរៀបចំដី

- កាប់ឬភ្ជួរដីរួចហាលដីរយៈពេលពី៧-១៥ថ្ងៃ បន្ទាប់មកភ្ជួររំព្រែរវា ២-៣ដងទៀត។
- កាប់ឬភ្ជួរដីឲ្យបានជម្រៅពី២០-២៥ស.ម រួចវាយបំបែកដីឲ្យម៉ដ្ត រើសយកស្មៅចេញឲ្យស្អាត។

## ២.២ ការលើករង

- ធ្វើរងទទឹងប្រវែង០,៨-១ម៉ែត្រ បណ្តោយតាមលទ្ធភាព
- កំពស់រងនៅរដូវប្រាំង ពី១៥-២០ស.ម
- កំពស់រងនៅរដូវវស្សា ពី២០-៣០ស.ម
- ចន្លោះពីរងមួយទៅរងមួយប្រវែង ៣០ ស.ម
- ដាក់ជីកំប៉ុស្តិ៍ទំងន់០,៥-១គីឡូក្រាមក្នុងមួយរណ្តៅហើយច្របល់ឱ្យសព្វ រួចកៀរ រាស់វាឲ្យបានស្មើល្អ។
- ជីករណ្តៅជម្រៅពី១៥-២០ ស.ម ជាពីរជួរដែលមានចន្លោះគុម្ពពី ៤០-៥០ស.ម និងចន្លោះជួ ពី៦០-៧០ស.ម។

## ២.៣ របៀបដាំដុះ

### ក-ការដាំគ្រាប់ដោយផ្ទាល់

- យកគ្រាប់ពូជទៅហាលថ្ងៃរយៈពេលពី១-២ម៉ោងរួចយកវាទៅត្រាំទឹកស្អាតរយៈពេលពី៣-៤ម៉ោង
- ត្រូវផ្អាប់គ្រាប់ពូជរយៈពេល១យប់ដើម្បីឲ្យគ្រាប់ងាយដុះពន្លក
- ដាក់ជីកំប៉ុស្តិ៍ដែលរលួយល្អចំនួន០,៥គីឡូក្រាមក្នុង១រណ្តៅ
- ដាក់គ្រាប់សណ្តែកដាំក្នុង១រណ្តៅចំនួន២-៣គ្រាប់ជម្រៅ៣ស.ម
- រោយដីមានជីជាតិនិងកំទេចចំបើងស្ងួតបន្តិចពីលើរណ្តៅ រួចស្រោចទឹកឲ្យបានជោគល្អ(ស្រោចព្រឹកល្ងាច)
- ក្រោយពីដាំបាន១៥ថ្ងៃត្រូវដកកូនរំលួស(ធីវកូន)ដើមណាដែលអន់ដកចេញទុកដើមណាដែលល្អ២-៣ដើមក្នុង១គុម្ព។

### ខ-ការបណ្តុះកូន

គេបណ្តុះកូនសណ្តែកទ្រើងដោយប្រើថង់ប្លាស្ទិកឬកន្តោងស្លឹកចេកដែលមានច្រកដីពេញដោយប្រើល្បាយរួមមាន៖

- ជីកំប៉ុស្តិ៍ឬជីលាមកសត្វ៥០ភាគរយ
- ដីដំបូកឬដីមានជីជាតិ២៥%

- ដីខ្សាច់ម៉ដ្តល្អ២៥%
- ដាក់គ្រាប់សណ្តែកក្នុងថង់ឬកន្ទោងចំនួន១-២គ្រាប់រួចស្រោចទឹកឲ្យជោគ(បាតថង់ឬកន្ទោងត្រូវជ្រាបទឹកបានល្អ)
- ក្រោយបណ្តុះបានពី៦-៧ថ្ងៃឬកូនសណ្តែកមានស្លឹកកំណើត២-៣សន្លឹកអាចយកវាទៅដាំបាន។

## គ-ការដាំកូន

- ជីករណ្តៅជាពីរជួរដែលមានចន្លោះរណ្តៅពី៤០-៥០ស.ម និងចន្លោះជួរពី៦០-៧០ស.ម
- ដាក់កូនសណ្តែកដាំ១-២ដើមក្នុងមួយរណ្តៅ
- ត្រូវយកកំទេចចំបើងខ្លីៗមកគ្របគល់សណ្តែកបន្ទាប់ពីដាំរួចភ្លាមដើម្បីការពារសំណើមរួចស្រោចទឹកភ្លាមឲ្យបានជោគល្អ។

## ៣.ការថែទាំ

### ៣.១ ការកំចាត់ស្មៅជ្រោយដីនិងពូនរង

- លើកទី១: ធ្វើវាបន្ទាប់ពីដាំបានរយៈពេលពី១០-១២ថ្ងៃ
- លើកទី២: ធ្វើវាក្រោយពេលជ្រោយដីលើកទី១បាន ១៥ថ្ងៃ ឬសណ្តែកអាយុបាន២៥ថ្ងៃ។

📖 លើកទី៣: ធ្វើវានៅពេលសណ្តែកអាយុបាន៤០ថ្ងៃ គឺគ្រាន់តែកាត់ស្មៅត្រឹមដីឬដកស្មៅទាំងឫសមិនចាំបាច់ជ្រោយគល់ទេ។

## ៣.២ ការដាក់ជី

ការប្រើជីទ្រាប់បាតគឺដាក់ជីកំប៉ុស្តិ៍ចំនួន០,៥-១គីឡូក្រាម ក្នុង១រណ្តៅដោយលាយច្របល់ជាមួយដីនៅក្នុងរណ្តៅ ។

## ៣.៣ ការដោតចំណារឬទ្រើងនិងការកាត់មែក

☺ យកកូនឈើនិងឫស្សីប្រវែងពី២-២,៥ម៉ែត្រមកធ្វើចំណារ

☺ ដោតប្រឈមមុខគ្នានៅពេលកូនសណ្តែកលូតលាស់បាន៤-៥សន្លឹក ដែលមានកំពស់១៥-២០ស.ម

☺ ក្រោយពេលដាំបាន២០-២៥ថ្ងៃឬពេលសណ្តែកបែកខ្នែងត្រូវរុំខ្នែង នឹងដើមរបស់វាឬរុំជាប់ទៅនឹងចំណារ

☺ ត្រូវកាត់សំអាតមែកតូចៗចេញទុកតែមែកចំបងហើយធ្វើវានៅពេលសណ្តែកមានអាយុ២០-២៥ថ្ងៃ

☺ កាត់ស្លឹកចាស់ៗដែលកើតជម្ងឺចោលដើម្បីកាត់បន្ថយការឆ្លងជម្ងឺកាត់បន្ថយជម្រកសត្វល្អិតនិងអាចស្រូបយកជីវជាតិពីដី។

## ៣.៤ ការស្រោចទឹក

☺ សណ្តែកក្ហួរត្រូវការទឹកជាប្រចាំតែមិនត្រូវការដក់ទឹកនៅក្នុងរងឬក្នុងចំការទេ

☺ យើងត្រូវស្រោចទឹក២ដងក្នុង១ថ្ងៃ នៅពេលព្រឹកនិងល្ងាច

☺ ចំពោះការបញ្ចូលទឹកត្រូវបញ្ចូល២ដងក្នុង១សប្តាហ៍ទៅតាមសភាពដី និងអាកាសធាតុ

☺ ត្រូវត្រួតពិនិត្យដីថាតើមានសំណើមគ្រប់គ្រាន់ឬទេ ជាពិសេសនៅពេលសណ្តែកចាប់ផ្តើមចេញផ្កា(អាយុ៣០ថ្ងៃ) រហូតដល់ពេលប្រមូលផល។

## ៩.ការប្រមូលផល

☺ យើងអាចប្រមូលផលបាននៅពេលសណ្តែកមានអាយុពី៦០-៧៥ថ្ងៃ ដោយចាប់គិតពីពេលដាំនិងទៅតាមប្រភេទពូជផងដែរ

☺ ការប្រមូលផលត្រូវធ្វើនៅពេលរសៀល

☺ គេមិនត្រូវក្តិចក្រោមទងស្នែងឬសន្តង់ទេ (លើសាច់សណ្តែកក្ហួរ) ព្រោះធ្វើឲ្យសណ្តែករក្សាទុកមិនបានយូរឬឆាប់ហើមនិងមិនគួរកាត់ទាំងទងស្នែងឬសន្តង់ទេព្រោះធ្វើឲ្យទងស្នែងឬសន្តង់នោះលែងចេញផ្កាតទៅទៀត។

☺ បេះផ្លែថ្មមៗ ដាក់ក្រោមម្លប់ ព្រោះវាអាចបែកញើសទៅជាពណ៌លឿងនាំឲ្យឆាប់ខូច

☺ យើងអាចប្រមូលផលបានចាប់ពី១៥-១៨លើកក្នុងមួយរដូវដាំដុះ។

## ៥.ការរក្សាពូជទុក

- ហាមទុកពូជចំពោះផ្លែណាដែលនៅក្បែរដី តែត្រូវទុកពូជចំពោះផ្លែណាដែលនៅខ្ពស់ផុតពីដី ក្លូរវែងល្អគ្មានជម្ងឺ និងគ្មានការបំផ្លាញពីពពួកសត្វល្អិតចង្រៃផ្សេងៗ
- រើសយកក្លួរសណ្តែកដែលផ្លែសារទី២-៤នៃដើម និងជ្រើសយក ២-៣ក្លួរប៉ណ្ណោះក្នុង១ដើម ទុកវាឲ្យទុំស្ងួតនៅលើដើមទើបយើងបេះវាមកហាលថ្ងៃឲ្យស្ងួតល្អ
- ញីបំបែកវាដើម្បីយកគ្រាប់ចេញ ហើយយកគ្រាប់នោះមកហាលថ្ងៃឲ្យស្ងួតម្តងទៀតរយៈពេល២-៣ថ្ងៃ
- ច្រកគ្រាប់ពូជទាំងនោះចូលក្នុងដប(ទុក១ភាគ៣នៃដប) ឬក្នុងថង់ក្រណាត់ហើយចងឬបិទឲ្យជិតរួចរក្សាទុកនៅកន្លែងមានសុវត្ថិភាពនិងមានខ្យល់ចេញចូលគ្រប់គ្រាន់
- រយៈពេល៣ឬ៤ខែត្រូវបញ្ចេញហាលថ្ងៃម្តង គឺរយៈពេល២-៣ម៉ោងធ្វើឲ្យគ្រាប់ពូជមានសុខភាពល្អរក្សាដំណុះបានយូរក្នុងករណីគ្រាប់នោះស្ងួតបានល្អអត្រាសំណើមពី១២-១៣ភាគរយ៕

**សូមអរគុណ**

កាលបរិច្ឆេទ: ថ្ងៃទី ០១ ខែឧសភា ឆ្នាំ២០១៨

# មេរៀនដំណាំស្ពៃតឿ

## ១.បច្ចេកទេសនៃការដាំស្ពៃតឿ

### ១.១-ការរៀបចំដី

- ត្រូវភ្ជួររាស់ដីហាលចោលចាប់ពី៧-១៥ថ្ងៃភ្ជួរដីជម្រៅពី១៥-៣០ស.ម
- ភ្ជួរប្រែវាឡើងវិញឲ្យបាន២-៣ដងដើម្បីត្រឡប់ស្មៅឬរុក្ខជាតិផ្សេងៗ ឲ្យត្រឡប់ទៅក្រោមនឹងឲ្យវារលួយទៅជាជី សម្លាប់ដង្កូវដឹកឡើ និងសត្វល្អិតដែលមាននៅក្នុងដី ហើយម៉្យាងទៀតធ្វើឲ្យដីធូរនិងមានខ្យល់អុកស៊ីសែនចេញចូលបានល្អ។

### ១.២-ការលើករង

- ធ្វើរងទទឹង ១ម៉ែត្រ បណ្តោយ១០ម៉ែត្រ ឬតាមលទ្ធភាព
- ចន្លោះពីរងមួយទៅរងមួយ ៣៥-៥០ស.ម គម្លាតពីគុម្ពមួយទៅគុម្ពមួយយកប្រវែង២តឹក (ទទឹងរង១ម៉ែត្រអាចដាំបានចំនួន ៣-៤ជួរ)។
- រដូវវស្សាអាចលើករងកំពស់២០-៣០ស.ម រាងខ្នងអណ្តើកឬខ្ពស់ជាងនេះទៅតាមស្ថានភាពដី។
- រដូវប្រាំងអាចលើករងកំពស់១៥-២០ស.ម រាងផតកណ្តាល។

រៀបចំដោយលោក យុគ សឿង នាយករងរបស់អង្គការស៊ីអារ៍ឌីណាស់ (CRDNASE)
កែសម្រួលអត្ថបទដោយ ស៊ុន សុគន្ធី មន្ត្រីគម្រោងរបស់អង្គការស៊ីអារ៍ឌីណាស់ (CRDNASE)

- ដាក់ជីធម្មជាតិឬជីកំប៉ុស្ដ៍សំរាប់ទ្រាប់បាតពី១០-១៥គីឡូក្រាម រួចច្របល់ជាមួយដីរងនោះអោយសព្វ។

## ១.៣-ការដាំដុះ

### ក- ការសាបគ្រាប់

- យកគ្រាប់មកហាលថ្ងៃរយៈពេល២០-៣០នាទី រួចយកវាទៅត្រាំទឹករយៈពេល៣ម៉ោង បន្ទាប់មកផ្អាប់វា១យប់ដើម្បីឲ្យគ្រាប់វារីក។
- ធ្វើថ្នាលឲ្យបានល្អ ដីម៉ត់ល្អ រួចយកគ្រាប់ស្ពៃមកលាយជាមួយដីខ្សាច់៤ភាគរួចច្របល់ឲ្យស្មើសាច់រួចយកវាទៅរោយលើថ្នាលឲ្យរង្វើលៗល្មម។
- យកផេះបាចជុំវិញថ្នាល ដើម្បីការពារសត្វស្រមោចពាំ។
- មួយបែបទៀត គឺពេលធ្វើរងរួចហើយ យកគ្រាប់ដែលត្រាំនឹងផ្អាប់រួចនោះទៅព្រោះពីលើរង បន្ទាប់មករោយកំទេចចំបើងពីលើរួចស្រោចទឹកជាការស្រេច។

### ខ- ការដកស្ទូង

- ការស្ទូងត្រូវធ្វើនៅពេលកូនស្ពៃមានអាយុពី១០-១៥ថ្ងៃ ឬពេលវាមានសន្លឹក៣ឬ៤។
- ផ្អាកស្រោចទឹករយៈពេល២ថ្ងៃ មុនពេលដកកូនទៅដាំដើម្បីធ្វើឲ្យកូនស្ពៃធន់ទៅនឹងកំដៅថ្ងៃ។

▪ មុននឹងដកត្រូវស្រោចទឹកលើថ្នាលកូនស្ពៃឲ្យបានសើមល្អ ដើម្បីងាយស្រួលក្នុងការដកកូនយកទៅស្ទូង។

▪ ត្រូវដកកូនបន្ទាប់ពីស្រោចទឹកភ្លាម។

▪ ស្ទូងចន្លោះពីគុម្ពមួយទៅគុម្ពមួយយកប្រវែង២០ស.ម និងចន្លោះរង ៣៥-៥០ស.ម។

▪ ត្រូវគ្របកូនសន្ទូង២-៣ថ្ងៃដើម្បីការពារកំដៅថ្ងៃ។

▪ បើភ្លៀងធ្លាក់ជោកជាំខ្លាំងក្នុងរង ត្រូវបង្ហូរទឹកចេញ។

▪ ត្រូវបង្កើនបរិមាណទឹកស្រោចចាប់ពីពេលស្ទូងរហូតដល់ពេលប្រមូលផល។

## ២.ការថែទាំ

### ២.១-ការកំចាត់ស្មៅនិងជ្រោយដី

▪ ការសំអាតស្មៅគឺធ្វើឡើងដោយដៃ ដោយចប ចបជីក ចបកាប់ និងបន្ទះឫស្សីសំរាប់ជ្រោយដី។ វិធីនេះងាយស្រួលក្នុងការអនុវត្តនៅជុំវិញរងនិងចន្លោះរង។

▪ ការជម្រះស្មៅនិងជ្រោយដីត្រូវធ្វើឡើងនៅពេលកូនស្ពៃស្ទូងបាន ១០ថ្ងៃ ហើយធ្វើដោយប្រុងប្រយត្ន័ កុំឲ្យប៉ះពាល់ឫស ជាហេតុនាំឲ្យអន់ឬងាប់កូនស្ពៃ។

- ការប្រមូលផលអាចប្រើកូនកាំបិទសំរាប់កាត់គល់។
-

## ២.២-ការស្រោចស្រប់

- ស្រោចទឹក១ថ្ងៃ២ដងនៅពេលព្រឹកនិងពេលល្ងាច
- នៅរដូវវស្សាបើមានភ្លៀងធ្លាក់ខ្លាំងក៏ដោយ គេក៏ត្រូវស្រោចទឹកដើម្បីលាងសំអាតកំទេចដីដែលមានជាប់ឬនៅបណ្តូលស្ពៃជាហេតុធ្វើឲ្យរលួយ។

## ២.៣-ការដាក់ជី

យើងប្រើជីកំប៉ុស្ត៍ពី០,៥-១គីឡូក្រាមលើផ្ទៃដី១ម៉ែត្រការ៉េ ដោយច្របល់ឲ្យសព្វរួចហើយស្រោចទឹកឲ្យជោគ។

## ៣.ការប្រមូលផល

- ការប្រមូលផលធ្វើឡើងតាមរបៀបផ្សេងៗគ្នាគេអាចដកទាំងឬសឬកាត់យកតែដើមក៏បាន វាអាស្រ័យទៅតាមតម្រូវការទីផ្សារ។
- មុននឹងកាត់ឬដកស្ពៃមិនត្រូវស្រោចទឹកឡើយដោយទុកឲ្យស្លឹកស្ពៃស្ងួតការពារជាំឬកកិត។
- ស្ពៃអាចប្រមូលផលបាននៅអាយុ៣០-៤០ថ្ងៃ ចំពោះស្ពៃសាបដោយផ្ទាល់និងនៅអាយុ៤០-៥០ថ្ងៃចំពោះស្ពៃដែលដកកូនទៅស្ទូង។

- គេអាចប្រមូលពេលព្រឹកឬល្ងាច ហើយទុកវាដាក់ក្នុងម្លប់ និងដាក់វាក្នុងល្អី កញ្ជេរឬ កេះដោយទ្រាប់ស្លឹកចេកផង។
- ទិន្នផលជាមធ្យមចន្លោះពី១៦-១៨តោនក្នុង១ហិកតាតែវាក៏អាស្រ័យលើការដាំដុះ ការថែទាំ និងប្រភេទពូជផងដែរ៕

**សូមអរគុណ**

រៀបចំដោយលោក យុគ សឿង នាយករងរបស់អង្គការស៊ីអាវ៍ឌីណាស់ (CRDNASE)
កែសម្រួលអត្ថបទដោយ ស៊ុន សុគន្ធី មន្ត្រីគម្រោងរបស់អង្គការស៊ីអាវ៍ឌីណាស់ (CRDNASE)